**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧១៥ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៤

# ប្រកាស
## ស្តីពី
## វិធានការជំរុញ និង ប្រមូលបំណុល ចំណូល ថ្លៃឈ្នួលរោងចក្រ សហគ្រាស និង អចលនវត្ថុរបស់រដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១នស / ៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- យោងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ៣០ប.ប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- យោងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៧ សរណន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤
- យោងសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩
- យោងកិច្ចសន្យាជួលរោងចក្រ សហគ្រាស និង អចលនវត្ថុ រវាងក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ជាមួយនឹងរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជន
- យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១** : ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ( ភាគី " ក " នៃកិច្ចសន្យាជួល រោងចក្រ សហគ្រាស និង អចលនវត្ថុ) ជាអ្នកជំរុញ និង ប្រមូលបំណុល ចំណូលថ្លៃឈ្នួល រោងចក្រ សហគ្រាស និង អចលនវត្ថុ ដែលបានជួលឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលជាភាគី " ខ " នៃកិច្ចសន្យា ។

**ប្រការ២** : ក្រសួង ស្ថាប័ន និង ខេត្ត ក្រុងទាំងអស់ ត្រូវចាត់ចែងឱ្យអ្នកជួលរោងចក្រ សហគ្រាស និង អចលនវត្ថុ អនុវត្តការបង់ប្រាក់ថ្លៃឈ្នួលជូនរដ្ឋដូចតទៅ:

- ត្រូវបង់ត្រង់ទៅថវិការដ្ឋតែម្តងចូលគណនីលេខ : ០២ -៣៥. ១២១១- T០២៣ នៅធនាគារជាតិនៃកម្ពុជា ចំពោះរាល់រោងចក្រ សហគ្រាស និង អចលនវត្ថុដែលមានទីតាំងនៅរាជធានីភ្នំពេញ ។ ទន្ទឹមនេះធនាគារជាតិនៃកម្ពុជាត្រូវធ្វើប្រកាសឥណទាន ឬ បង្កាន់ដៃបង់ប្រាក់ចំនួនបីច្បាប់ ដែលក្នុងនោះមួយច្បាប់ផ្ញើជូន ៖

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ(នាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ ) និង មួយច្បាប់ផ្ញើជូនសាមុីក្រសួង ឬ ស្ថាប័នដែលជាភាគី "ក" នៃកិច្ចសន្យា( នាយកដ្ឋាន គណនេយ្យ និង ហិរញ្ញវត្ថុ) ហើយមួយច្បាប់ទៀតផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលបានបង់ប្រាក់ថ្លៃឈ្នួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ ។

-ត្រូវបង់ចូលគណនីថវិការដ្ឋនៅរតនាគារខេត្ត ក្រុងតែម្តង ចំពោះរោងចក្រ សហគ្រាស ឬ អចលនវត្ថុដែលមានទីតាំងនៅតាមខេត្ត ក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញ ។ រតនាគារខេត្ត ក្រុងត្រូវធ្វើសាលាកប័ត្របង់ប្រាក់ចូលថវិការដ្ឋចំនួនបីច្បាប់ ក្នុងនោះមួយច្បាប់ផ្ញើជូនមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មួយច្បាប់ផ្ញើជូនមន្ទីរ ឬ អង្គភាពជំនាញរបស់ក្រសួង ឬ ស្ថាប័ន និង មួយច្បាប់ទៀតផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនដែលបានបង់ប្រាក់ថ្លៃឈ្នួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ ។

ប្រការ៣ : -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ" ជាអ្នកតាមដាន និង កត់ត្រានូវបំណុល ចំណូលថ្លៃឈ្នួល ព្រមទាំងមានវិធានការលើការជំរុញ និង ប្រមូលបំណុល ចំណូលថ្លៃឈ្នួលខាងលើនេះ រួមទាំងធ្វើការណែនាំផ្ទាល់ទៅគ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ឱ្យអនុវត្តតាមកិច្ចសន្យាដែលនៅជាធរមាន ។

-អនុលោមមាត្រា៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០១ នស៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ មាត្រាទី១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ និង មាត្រាទី៧ និង ទី១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ប្រសិនបើក្នុងរយៈពេល៣០ថ្ងៃចាប់ពីថ្ងៃដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុណែនាំដល់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ដែលជាភាគី "ក" នៃកិច្ចសន្យាឱ្យមានវិធានការលុបកិច្ចសន្យាប៉ុន្តែនៅតែមិនព្រមមានវិធានការនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងបន្តលើកករណីនោះគោរពជូនសម្តេចនាយករដ្ឋមន្ត្រីដើម្បីចាត់វិធានការជាចុងក្រោយ ។

ប្រការ៤ : រាល់ការស្នើសុំជួល សុំបញ្ចុះថ្លៃឈ្នួល ពន្យាររយៈពេលកិច្ចសន្យាជួល និង សុំរួចថ្លៃឈ្នួលក្នុងរយៈពេលរុះរើជួសជុល និង សាងសង់លើទីតាំងដែលបានជួលពីរដ្ឋ ត្រូវតែអនុវត្តតាមនីតិវិធីនៃបទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងបទបញ្ញត្តិ និង នីតិវិធីជាធរមាន ។

ប្រការ៥ : គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត ក្រុង ដែលមានជួលរោងចក្រ សហគ្រាស ឬ អចលនវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ៦ : រាល់ប្រកាស រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អន្តរក្រសួង ស្ថាប័ន ស្តីពីវិធានការប្រមូលចំណូលថ្លៃឈ្នួលអចលនវត្ថុដែលមានន័យផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តជាតតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ធនាគារជាតិនៃកម្ពុជា
-ក្រសួង ស្ថាប័ន ពាក់ព័ន្ធ "ដូចប្រការ៥"
-សាលាខេត្ត-ក្រុង ពាក់ព័ន្ធ "ដូចប្រការ៥"
-មន្ទីរ អង្គភាព ពាក់ព័ន្ធ
-រតនាគារខេត្ត-ក្រុង ពាក់ព័ន្ធ
-រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជននៃកិច្ចសន្យា
-ឯកសារ